**ប្រកាសទទួលសំណើ៖** សមាគមស៊ីកាដាកំពុងស្វែងរកសំណើសម្រាប់តួនាទី **«ទីប្រឹក្សាពិនិត្យ និងចងក្រងគោលនយោបាយ»** ដើម្បីពិនិត្យ ចងក្រង និងបង្កើតបញ្ជីគោលនយោបាយទាក់ទងនឹងស្ថានភាពសិល្បករ (សម្រាប់ប្រទេសកម្ពុជា)

**<u>បរិបទ៖</u>**

សមាគមស៊ីកាដា (សមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកៃច្នៃនៃកម្ពុជា) ជាសមាគមដែលទើបបង្កើតថ្មី ដែលចង់មើលឃើញវិស័យវប្បធម៌ និងច្នៃប្រតិដ្ឋរីកចម្រើន, ចម្រុះ, និងមានសិទ្ធិអំណាច ដែលចូលរួមដល់ភាពរីកចម្រើននៃសង្គមកម្ពុជា។ បេសកកម្មរបស់យើងគឺធ្វើឱ្យមានផលប៉ះពាល់ជះលើគោលនយោបាយជាតិ តាមរយៈការស្រាវជ្រាវ ការកសាងសមត្ថភាព និងការសន្ទនានានា ដើម្បីនាំឱ្យមានការអភិវឌ្ឍ និងការរីកចម្រើននៃឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋ (CCIs) ដែលមានការទទួលស្គាល់ជាតិ និងពិភពលោក មកលើសិល្បៈ វប្បធម៌ និងច្នៃប្រតិដ្ឋរបស់កម្ពុជា។ CICADA មានអាទិភាពជាយុទ្ធសាស្ត្រចំនួនប្រាំគឺ៖ ការតស៊ូមតិ និងគោលនយោបាយ ការស្រាវជ្រាវ សមាជិកភាព ភាពជាដៃគូក្នុងឧស្សាហកម្ម និងការអភិវឌ្ឍសមាគម។

នៅឆ្នាំ២០២៣ សមាគមស៊ីកាដាទទួលបានជំនួយពី UNESCO Aschberg ដើម្បីអនុវត្តគម្រោង «ការកសាងចំណេះដឹងមូលដ្ឋាន ដើម្បីកែលម្អស្ថានភាពសិល្បករនៅកម្ពុជា»។ គម្រោងនេះមានគោលបំណងលើកកម្ពស់សេរីភាពសិល្បៈនៅកម្រិតថ្នាក់ជាតិក្នុងប្រទេសកម្ពុជា ដោយរកឱ្យឃើញនូវចន្លោះប្រហោងនៃព័ត៌មាន ដែលកម្រិតសមត្ថភាពរបស់សង្គមស៊ីវិល មិនអាចតស៊ូមតិប្រកបដោយប្រសិទ្ធភាពសម្រាប់កែលម្អគោលនយោយ ដែលពាក់ព័ន្ធនឹងឧស្សាហកម្មវប្បធម៌ និងច្នៃប្រតិដ្ឋ ជាពិសេសស្ថានភាពរបស់សិល្បករ។

ដើម្បីចាប់យកទិដ្ឋភាពរួមនៃស្ថានភាពឧស្សាហកម្មច្នៃប្រតិដ្ឋ វប្បធម៌ និងសិល្បករ សមាគមស៊ីកាដាកំពុងស្វែងរកអ្នកប្រឹក្សាយោបល់ ដើម្បីពិនិត្យគោលនយោបាយជាច្រើន និងចងក្រងជាបញ្ជីនៃច្បាប់ គោលនយោបាយថ្នាក់ជាតិ និងអន្តរជាតិទាំងឡាយណា ដែលទាក់ទងនឹងស្ថានភាពនៃសិល្បករនៅកម្ពុជា។

ជាទូទៅមិនត្រឹមតែសហគមន៍សិល្បៈនោះទេ ដែលមិនបានដឹងពីគោលនយោបាយ ឬច្បាប់នានា ដែលមានស្រាប់ និងដែលពាក់ព័ន្ធនឹងពួកគេប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងខ្វះចំណេះដឹងអំពីទំនួលខុសត្រូវរបស់ពួកគេផងដែរ ឧទាហរណ៍ មិនមានព័ត៌មានច្បាស់លាស់ក្នុងការអនុវត្តការងារជាដើម។ ប្រការនេះធ្វើឱ្យប្រតិបត្តិករវប្បធម៌ រួមទាំងសិល្បករ ប្រឈមមុខនឹងហានិភ័យក្នុងការមិនគោរពតាមច្បាប់ ឬមិនអាចអនុវត្តសិទ្ធិ និងការការពារពេញលេញ ដែលពួកគេមានសិទ្ធិទទួលបាន។

## វិសាលភាពនៃការងារ

**គោលដៅ៖** លទ្ធផលចុងក្រោយនៃកិច្ចការនេះគឺជាបញ្ជីនៃគោលនយោបាយដែលងាយស្រួលប្រើប្រាស់ ស្វែងរក ឬអាន ជាភាសាខ្មែរ និងអង់គ្លេស ដែលអាចបោះពុម្ពលើគេហទំព័រ សមាគមស៊ីកាដា និងអាចប្រើប្រាស់បានដោយសមាជិករបស់ CICADA ដែលភាគច្រើនជាប្រតិបត្តិករវប្បធម៌ក្រៅផ្លូវការ សិល្បករឯករាជ្យ អង្គការសិល្បៈ និងវប្បធម៌ និងអង្គការសង្គមស៊ីវិល ទីភ្នាក់ងារ ឬរដ្ឋាភិបាលផ្សេងទៀតដែលធ្វើការលើប្រធានបទនេះ។

**គោលបំណង៖**

- អាចជួយ CICADA ឱ្យមានលទ្ធភាពផ្តល់ជូននូវបញ្ជីគោលនយោបាយ ឬច្បាប់ ទាក់ទងនឹងវិស័យសិល្បៈ និងវិស័យច្នៃប្រតិដ្ឋ ដល់សមាជិក សហគមន៍សិល្បៈ អ្នកស្រាវជ្រាវ និងអ្នកតស៊ូមតិផ្នែកសិល្បៈ
- រួមចំណែកធ្វើឱ្យប្រសើរឡើងនៃទិដ្ឋភាពទូទៅនៃគោលនយោបាយទាក់ទងនឹងវិស័យសិល្បៈ

**តួនាទី៖**

ទីប្រឹក្សាត្រូវបានរំពឹងថានឹង៖

- ពិនិត្យពិច្ច័យដើម្បីកំណត់នូវបញ្ជី (ឬតារាង) ដ៏ទូលំទូលាយមួយអំពីច្បាប់ និងគោលនយោបាយជាតិ និងអន្តរជាតិ ដែលពាក់ព័ន្ធចំពោះប្រតិបត្តិករ ដែលធ្វើការក្នុងវិស័យសិល្បៈនៅកម្ពុជា។ វានឹងរួមបញ្ចូលទាំងគោលនយោបាយទាក់ទងនឹងវិស័យសិល្បៈ ដូចជាកម្មសិទ្ធិបញ្ញា សិទ្ធិអ្នកនិពន្ធ ច្បាប់ការងារ អាជ្ញាប័ណ្ណ ប្រព័ន្ធការពារសង្គម សិទ្ធិវប្បធម៌ សិទ្ធិមនុស្សជាដើម)
- រៀបចំព័ត៌មាននេះទៅក្នុងបញ្ជីដែលងាយស្រួលអាន ងាយរកព័ត៌មាន និងងាយប្រើប្រាស់ដោយសមាជិក និងអ្នកពាក់ព័ន្ធរបស់ CICADA ។ បញ្ជីឈ្មោះទំនងជាត្រូវបានរៀបចំជាប្រភេទ ឬក្រុម (ការងារ ច្នៃប្រតិដ្ឋ ពន្ធ...)
  - ឈ្មោះច្បាប់ ឬគោលនយោបាយ
  - ស្ថាប័នដែលសរសេរ ឬអនុមតិច្បាប់ ឬគោលនយោបាយ
  - ព័ត៌មានបឋមពីច្បាប់ ឬគោលនយោបាយ (អាចអនុវត្តចំពោះប្រតិបត្តិករវប្បធម៌)
  - តំណភ្ជាប់ ឬព័ត៌មានអំពីរបៀបស្វែងរកព័ត៌មានលម្អិតពេញលេញនៃច្បាប់ ឬគោលនយោបាយ

**<u>ពេលវេលាសំខាន់ៗ៖</u>**

ទីប្រឹក្សាគឺរំពឹងថានឹងអាន ស្វែងរក ចងក្រង និងបង្កើតបញ្ជីគោលនយោបាយទាក់ទងនឹងស្ថានភាពសិល្បករ។ ការប៉ាន់ស្មាននៃការប្រឹក្សានេះគឺ ១០ ទៅ ១២ ថ្ងៃធ្វើការក្នុងរយៈពេល ៦ ខែ។

| | |
|---|---|
| ខែតុលា 2023: | ជួបប្រឹក្សាជាមួយក្រុមការងារ CICADA ដើម្បីបញ្ជាក់ និងកំណត់ការរំពឹងទុក |
| ខែវិច្ឆិកា - ធ្នូ 2023: | ទីប្រឹក្សាធ្វើការត្រួតពិនិត្យ និងប្រមូលគោលនយោបាយពាក់ព័ន្ធ |
| ខែមករា - កុម្ភៈ 2024: | ដំឡើងជាបញ្ជីតាមចំណាត់ថ្នាក់នៃគោលនយោបាយ (ជជែកជាមួយ CICADA មុន) |
| ខែមីនា 2024 | ដាក់ស្នើបញ្ជីគោលនយោបាយដែលបានព្រាង និងបង្ហើយការងារនេះ និងចុះហត្ថលេខាអនុមតិដោយ CICADA |

បញ្ជីគោលនយោបាយនេះនឹងត្រូវបកប្រែដើម្បីឱ្យមានជាភាសាខ្មែរ និងអង់គ្លេស។ អ្នកប្រឹក្សាអាចប្រើជាភាសាខ្មែរ ឬភាសាអង់គ្លេស។ ប្រសិនបើអ្នកប្រឹក្សាអាចមានលទ្ធភាព និងឆន្ទៈក្នុងការបកប្រែ សូមកត់សម្គាល់ចំណុចនេះ ហើយបញ្ចូលតម្លៃនៃការបកប្រែនៅក្នុងសំណើនេះបន្ថែម។

**<u>ថវិកា៖</u>**

តម្លៃសម្រាប់គម្រោងនេះគឺ **$3,000 USD** ដែលពន្ធកាត់ទុកនឹងត្រូវបង់ដោយ CICADA ជំនួសអ្នកប្រឹក្សា ដែលនឹងត្រូវកាត់ចេញពីតម្លៃខាងលើ។

**<u>ជំនាញ និងបទពិសោធន៍សំខាន់ៗ៖</u>**

- មានបទពិសោធន៍ស្រាវជ្រាវពីមុន
- មានសមត្ថភាពក្នុងការបង្កើតបញ្ជី ដែលងាយស្រួលរុករក និងងាយស្រួលអានសម្រាប់អ្នកប្រើប្រាស់
- អាចគិតគូរអំពីរូបភាពធំ នៃការប្រើប្រាស់គោលនយោបាយ
- អាចដាក់ខ្លួនគាត់នៅក្នុងស្ថានភាពរបស់មនុស្ស ដែលមិនធ្លាប់ ឬមិនសូវចាប់អារម្មណ៍លើគោលនយោបាយ

**<u>ជំនាញផ្សេងទៀត ដែលចង់បាន៖</u>**

- មានចំណាប់អារម្មណ៍ខ្លាំងលើគោលនយោបាយសាធារណៈ ជាពិសេសគោលនយោបាយទាក់ទងនឹងសិល្បៈ និងវប្បធម៌
- មានបទពិសោធន៍ការងារក្នុងវិស័យសិល្បៈកម្ពុជា
- មានចំណេះដឹងទូលំទូលាយអំពីគោលនយោបាយ និងច្បាប់ក្នុងតំបន់ និងអន្តរជាតិអំពីសិល្បៈ និងគោលនយោបាយដែលពាក់ព័ន្ធនឹងសិល្បៈ

**<u>សេចក្ដីណែនាំអំពីកម្មវិធី៖</u>**

ដើម្បីដាក់ពាក្យទទួលការងារនេះ សូមផ្ញើ៖

- លិខិតមួយច្បាប់ ដែលពន្យល់ពីចំណាប់អារម្មណ៍ និងលក្ខណៈសម្បត្តិរបស់អ្នកប្រឹក្សាសម្រាប់កិច្ចការនេះ
- សំណើ (អតិបរមា ២ ទំព័រ) ពន្យល់ពីរបៀបដែលអ្នកប្រឹក្សានឹងធ្វើ/បំពេញការងារនេះ
- ប្រវត្តិរូប ដែលមានអ្នកអាចផ្ដល់មតិយោបល់អំពីបទពិសោធន៍ ចំនួន ពីរនាក់

សូមផ្ញើឯកសារទាំងនេះមកកាន់ Info@cicadakh.org ត្រឹមថ្ងៃទី **20 ខែតុលា ឆ្នាំ 2023**។

ពាក្យសុំអាចជាភាសាអង់គ្លេស និងខ្មែរ។ គម្រោងនេះនឹងត្រូវការទំនាក់ទំនងជាភាសាខ្មែរ និងភាសាអង់គ្លេស។

*«គម្រោងនេះនឹងអនុវត្តក្រោមកម្មវិធីនៃយូណេស្កូ Aschberg ដែលមានគោលបំណងគាំទ្រដល់ការរចនាសេចក្ដីណែនាំថ្មីៗ ដើម្បីការពារ និងលើកកម្ពស់សេរីភាពនៃសិល្បៈ និងស្ថានភាពសិល្បករ និងប្រតិបត្តិករវប្បធម៌»។*